# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
# ស្តីពី
# ការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលតទៅនេះ ហៅថា "**ភាគីទាំងពីរ**"។

**ដោយព្រួយបារម្ភយ៉ាងខ្លាំង**អំពីឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលកំពុងតែរំលោភសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើឱ្យខូចខាតដល់សណ្តាប់ធ្នាប់សង្គម

**ដោយផ្អែកលើ**គោលការណ៍គោរពគ្នាទៅវិញទៅមកចំពោះឯករាជ្យភាព អធិបតេយ្យភាព សមភាព និងផលប្រយោជន៍រួម ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់រវាងភាគីទាំងពីរ ដើម្បីទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសអំពើជួញដូរមនុស្សឆ្លងដែន និងផ្តល់កិច្ចការពារ ព្រមទាំងផ្តល់ជំនួយចាំបាច់ប្រកបដោយប្រសិទ្ធិភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ៖**

## មាត្រា ១
## និយមន័យ

ចំពោះកិច្ចព្រមព្រៀងនេះ អំពើជួញដូរមនុស្សគប្បីកំណត់និយមន័យតាមច្បាប់ជាតិពាក់ព័ន្ធរបស់ភាគីទាំងពីរ ។

## មាត្រា២
## វិសាលភាពនៃកិច្ចសហប្រតិបត្តិការ

ភាគីទាំងពីរ គប្បីអនុវត្តកិច្ចសហប្រតិបត្តិការនេះលើផ្នែកនានាដូចខាងក្រោមដោយអនុលោមតាមច្បាប់ជាតិរបស់ភាគីទាំងពីរ និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានាដែលភាគីទាំងពីរបានព្រមព្រៀងអនុវត្ត៖

ក- ការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្មជួញដូរមនុស្ស

ខ- ការស៊ើបអង្កេត និងផ្តន្ទាទោសករណីជួញដូរមនុស្ស

គ- ការការពារ ផ្តល់ជំនួយ និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឃ- កសាងសមត្ថភាពលើផ្នែកបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## មាត្រា ៩

## ការរក្សា សម្ងាត់

ភាគីទាំងពីរត្រូវគោរពតាមគោលការណ៍នៃការរក្សាសម្ងាត់ដែលទាក់ទងនឹងប្រភព និងព័ត៌មានដែលបានផ្លាស់ប្តូរដោយភាគីទាំងពីរ។ គ្មានព័ត៌មានណាមួយដែលទទួលបាន ត្រូវបានបើកចំហដល់ភាគីទីបីដោយគ្មានការឯកភាពជាលាយលក្ខណ៍អក្សរពីភាគីដែលជាអ្នកផ្តល់ឡើយ។

## មាត្រា១០

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៅក្រោមសន្ធិសញ្ញាអន្តរជាតិផ្សេងទៀតដែលភាគីណាមួយ ក្នុងចំណោមភាគីទាំងពីរបានព្រមព្រៀងអនុវត្តនោះឡើយ។

## មាត្រា១១

## ការដោះស្រាយវិវាទ

ការខ្វែងគំនិតគ្នាណាមួយរវាងភាគីទាំងពីរដែលកើតចេញពីការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះនឹងត្រូវដោះស្រាយតាមរយៈការពិភាក្សា ក្នុងស្មារតីមិត្តភាព និងការយោគយល់គ្នាទៅវិញទៅមក។

## មាត្រា១២

## អវសានប្បញ្ញត្តិ

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ។

កិច្ចព្រមព្រៀងនេះនឹងអាចធ្វើវិសោធនកម្មក្រោយមានការពិភាក្សាដោយការព្រមព្រៀងគ្នាទៅវិញទៅមក។

ភាគីណាមួយអាចជូនដំណឹងដល់ភាគីម្ខាងទៀតជាលាយលក្ខអក្សរ តាមរយៈមធ្យោបាយការទូតអំពីការបិទបញ្ចប់កិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀងនេះនឹងក្លាយជាមោឃៈក្នុងរយៈពេល ៩០ ថ្ងៃក្រោយពេលដែលភាគីម្ខាងទៀតទទួលបានការជូនដំណឹងនេះ។

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើនៅ......................ថ្ងៃទី ................................ជា ភាសាខ្មែរ ភាសាចិន និងភាសាអង់គ្លេស។ អត្ថបទជាភាសាទាំងនេះមានតម្លៃដូចគ្នា។ ឯកសារជាភាសារអង់គ្លេសនឹងត្រូវយកមកប្រើប្រាស់ ក្នុងករណីមានការខ្វែងគំនិតគ្នាក្នុងការបកស្រាយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

| តំណាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន | តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
|---|---|

ភាគីនីមួយៗ ត្រូវអនុវត្តឱ្យបានពេញលេញនូវដំណើរការផ្ទៀងផ្ទាត់ដែលទាក់ទងនឹងសញ្ញាតិ និង អត្តសញ្ញាណជនរងគ្រោះ ហើយជូនដំណឹងដល់ភាគីដែលជាអ្នកស្នើសុំអំពីលទ្ធផលនៅក្នុងរយៈពេល៣០ថ្ងៃ ក្រោយបានទទួលការស្នើសុំ។

នៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍ ភាគីនីមួយៗត្រូវជូនដំណឹងជាមុនដល់ភាគីម្ខាងទៀតអំពីឈ្មោះនិង ព័ត៌មានចាំបាច់ដទៃទៀត តាមរយៈយន្តការសហប្រតិបត្តិការកិច្ចការនគរបាល ឬ មធ្យោបាយការទូត។

## មាត្រា៦

## វិធានការស៊ើបអង្កេត និងផ្តន្ទាទោស

ភាគីទាំងពីរត្រូវធ្វើសហប្រតិបត្តិការជិតស្និទ្ធដើម្បីស្រាវជ្រាវរកឲ្យឃើញ និងបង្រ្កាបអំពើជួញដូរមនុស្ស ឆ្លងដែន ជាពិសេសការជួញដូរកុមារ និងស្ត្រី។

ស្ថាប័នពង្រឹងការអនុវត្តច្បាប់នៃភាគីទាំងពីរ ត្រូវធ្វើសហប្រតិបត្តិការនៅក្នុងការស៊ើបអង្កេត ការផ្លាស់ប្តូរ ព័ត៌មាន និងភស្តុតាង ព្រមទាំងការប្រគល់ជនសង្ស័យក្នុងករណីជួញដូរមនុស្ស។

## មាត្រា៧

## ការអនុវត្ត

អាជ្ញាធរមានសមត្ថកិច្ចសម្រាប់កិច្ចព្រមព្រៀងនេះគឺ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំកិច្ចប្រជុំពិគ្រោះ យោបល់ប្រចាំឆ្នាំ នៅក្នុងប្រទេសទាំងពីរ ដោយប្តូរវេនគ្នា ដើម្បីពិភាក្សាអំពីបញ្ហាទាក់ទងនឹងការបង្ការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងករណីបន្ទាន់ ភាគីទាំងពីរអាចព្រមព្រៀងគ្នា រៀបចំកិច្ចប្រជុំបន្ថែមដោយ កំណត់ពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំទាំងនេះ ។

ប្រតិភូដែលទទួលសេចក្តីអញ្ជើញនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវរ៉ាប់រងការចំណាយលើមធ្យោបាយធ្វើ ដំណើរជាអន្តរជាតិ។ ថ្លៃចំណាយ ក្នុងរយៈពេលនៃការស្នាក់នៅរបស់ប្រតិភូនេះ ត្រូវតែជាបន្ទុករបស់ភាគី ជាអ្នក ចាត់អញ្ជើញលើកលែងតែមានការឯកភាពគ្នាដោយភាគីទាំងពីរ។

## មាត្រា៨

## ការបដិសេធសំណើ

ចំពោះការអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីដែលបានទទួលការស្នើ សុំអាចបដិសេធការផ្តល់ជំនួយដល់ភាគី អ្នកស្នើសុំ ប្រសិនបើភាគីដែលបានទទួលការស្នើសុំយល់ឃើញថា ជំនួយដែលស្នើឡើងដោយភាគីម្ខាងទៀតអាចនាំ ឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ផលប្រយោជន៍ជាមូលដ្ឋាន ឬ គោលការណ៍ច្បាប់របស់ខ្លួន ហើយភាគីអ្នកស្នើសុំនឹងត្រូវបានជូនដំណឹងអំពីហេតុផលនៃការបដិសេធនេះ។

## មាត្រា៣
## វិធានការបង្ការទប់ស្កាត់

ភាគីទាំងពីរគប្បីប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីបង្ការទប់ស្កាត់ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ តាមរយៈវិធានការបង្ការ ទប់ស្កាត់នានាដូចតទៅ៖

ក) បង្កើត និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររួមគ្នាដើម្បីបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសការជួញដូរមនុស្សក្រោមទម្រង់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ និង/ឬអាពាហ៍ពិពាហ៍ក្លែងក្លាយ

ខ) បង្កើនសេវាកម្មសង្គមដើម្បីគាំពារក្រុមជនងាយរងគ្រោះ

គ) ផ្លាស់ប្តូររបៀបអនុវត្តល្អៗ ព័ត៌មាន ឬទិន្នន័យ និងបទពិសោធន៍ សំខាន់ៗ ស្តីពីការបង្ការទប់ស្កាត់។

## មាត្រា៤
## វិធានការការពារ

ភាគីទាំងពីរត្រូវរួមគ្នាចាត់វិធានការសមស្រប ដើម្បីកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយត្រូវចាត់ទុកជនទាំងនោះជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស តែមិនមែនជាជនល្មើសឬជនសង្ស័យក្នុងករណីព្រហ្មទណ្ឌឡើយ ដូច្នេះ៖

ក) មិនមានភាគីណាមួយ ដាក់ទណ្ឌកម្មជនរងគ្រោះចំពោះការចេញ-ចូលដោយខុសច្បាប់ ក្នុងទឹកដីរបស់ខ្លួន ឬបទល្មើសទាំងឡាយដែលកើតចេញផ្ទាល់ពីការជួញដូរមនុស្សនៅក្នុងអំឡុងពេលដែលពួកគេស្នាក់នៅក្នុងប្រទេសចិននិង/ឬប្រទេសកម្ពុជាឡើយ។

ខ) នៅមុន និង ក្នុងអំឡុងពេលនៃដំណើរការធ្វើមាតុភូមិនិវត្តន៍ អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធនៃភាគីទាំងពីរ ត្រូវផ្តល់ជំនួយសមស្របដល់ជនរងគ្រោះទៅតាមអាយុនិងយេនឌ័ររបស់ពួកគេតាមលទ្ធភាពដែលអាចធ្វើបាន និង មិនកម្រិតត្រឹមតែការផ្តល់ទីជម្រក ជំនួយផ្នែកច្បាប់ ការថែទាំសុខភាព ការប្រឹក្សាយោបល់ និងការគាំទ្រជាសេវាសង្គមសមស្របនោះឡើយ។

គ) ភាគីទាំងពីរត្រូវធានាសន្តិសុខ និងសិទ្ធិឯកជនភាពរបស់ជនរងគ្រោះនៅក្នុងដំណើរការនេះ។

ឃ) នៅក្នុងដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការផ្តល់ជំនួយបណ្តោះអាសន្ន ការធ្វើមាតុភូមិនិវត្តន៍ និងដំណើរការតាមនីតិវិធីច្បាប់ ជនរងគ្រោះ គប្បីទទួលបាននូវការប្រព្រឹត្តដែលប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរ។

## មាត្រា៥
## វិធានការធ្វើមាតុភូមិនិវត្តន៍

ភាគីទាំងពីរត្រូវសហប្រតិបត្តិការដើម្បីធានាសុវត្ថិភាព និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះឱ្យបានសមស្របនិងទាន់ពេលវេលាដោយផ្អែកតាមនីតិវិធីធ្វើមាតុភូមិនិវត្តន៍ងាយៗដែលបានព្រមព្រៀងគ្នា។

## កំណត់ហេតុនៃកិច្ចប្រជុំពិនិត្យបញ្ចប់សេចក្តីព្រាង
## នៃ
## កិច្ចព្រមព្រៀង
## រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## និង
## រដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន
## ស្តីពី
## ការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ខេត្តសៀមរាប ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៦

បន្ទាប់ពីកិច្ចប្រជុំពិភាក្សាសេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពី «ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការ បង្ការទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងអំពីជួញដូរមនុស្ស» នៅក្រុងណានឆាង ខេត្តជាំងស៊ី ប្រទេសចិន កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៥កន្លងមក ភាគីទាំងពីរបានព្រមព្រៀង ដើម្បីពិនិត្យបញ្ចប់សេចក្តីព្រាង ពីថ្ងៃទី២៤ ដល់ ២៦ ខែសីហា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

គណៈប្រតិភូអន្តរក្រសួងរបស់ភាគីចិន រួមមានតំណាងមកពីក្រសួងសន្តិសុខសាធារណៈ ក្រសួងការបរទេស ក្រសួងកិច្ចការស៊ីវិល ការិយាល័យរបស់គណៈកម្មាធិការជាតិធ្វើការងារដើម្បីកុមារនិងស្ត្រី សហព័ន្ធនារីរបស់ចិន ស្នងការដ្ឋានសន្តិសុខសាធាណៈ ខេត្តជាំងស៊ី ស្នងការដ្ឋានសន្តិសុខសាធារណៈ ខេត្ត ក្វាងទុង ការិយាល័យសន្តិសុខសាធារណៈក្រុង សៀងហៃ ដែលដឹកនាំដោយលោក ឆេនស៊ីគួ អគ្គនាយករងនៃអគ្គនាយកដ្ឋានស៊ើបអង្កេត របស់ក្រសួងសន្តិសុខសាធារណៈ ។

គណៈប្រតិភូអន្តរក្រសួងរបស់ភាគីកម្ពុជា រួមមានតំណាងមកពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងការបរទេសកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គស្នងការដ្ឋាននគរបាលជាតិ និង

នាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្សនិងការពារអនីតិជន និងអាជ្ញាធរខេត្តសៀមរាប ដែលដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ក្រោយពីមតិស្វាគមន៍របស់លោកជំទាវអភិបាលរងខេត្តសៀមរាប ចំណាប់អារម្មណ៍ ថ្លែងដោយប្រធានគណៈប្រតិភូចិននិងសុន្ទរកថាបើកកិច្ចប្រជុំ ដោយប្រធានគណៈប្រតិភូកម្ពុជារួចមក គណៈប្រតិភូទាំងពីរបានពិភាក្សាគ្នា និងសម្រេចលើចំណុចសំខាន់ៗដូចខាងក្រោម៖

1) បានពិនិត្យ បញ្ជាប់ និងរៀបចំឱ្យមានសេចក្តីព្រាងនៃកិច្ចព្រមព្រៀងជាបីភាសា៖ ចិន ខ្មែរនិងអង់គ្លេសដែលមានតម្លៃស្មើគ្នា
2) ព្រមព្រៀងគ្នាលើសកម្មភាពដែលបានស្នើឡើងចំនួនប្រាំសម្រាប់ឆ្នាំ២០១៧ដែលរួមមាន
   - ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនឱ្យហួសពីឆ្នាំ២០១៦
   - រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំលើកទី១ នៅក្នុងប្រទេសចិន នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៧ (ពិនិត្យបញ្ជាប់ផែនការសកម្មភាពឆ្នាំ២០១៧)
   - តែងតាំងជនបង្គោលសម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគី
   - ធ្វើកិច្ចប្រតិបត្តិការអនុវត្តច្បាប់រួមគ្នា ពីខែឧសភាដល់ខែកក្កដាឆ្នាំ២០១៧
   - រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការពង្រឹងការអនុវត្តច្បាប់ រួមគ្នា ធ្វើនៅ ប្រទេសចិន
3) ឯកភាពពិនិត្យឡើងវិញនូវសេចក្តីព្រាងនីតិវិធី ប្រតិបត្តិបទដ្ឋាន សម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំនៅត្រីមាសទី១ ឆ្នាំ២០១៧

កំណត់ហេតុនេះនឹងសរសេរជាភាសាចិន ខ្មែរ និងអង់គ្លេស។

ប្រធានគណៈប្រតិភូចិន

陈士渠

**លោក ឆេន ស៊ីគូ**

អគ្គនាយករងនៃអគ្គនាយកដ្ឋានស៊ើបអង្កេតព្រហ្មទណ្ឌរបស់ក្រសួងសន្តិសុខសាធារណៈ

ប្រធានគណៈប្រតិភូកម្ពុជា

**លោកជំទាវ ជូ ប៊ុនអេង**

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

និងជាអនុប្រធានអចិន្ត្រៃយ៍ នៃ គ.ជ.ប.ជ